**សំរេច**

ប្រការ ១ : ប្រគល់ភារកិច្ចជូនឯកឧត្តម ស៊ុយ សែម រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារនិងអតីតយុទ្ធជន ជារដ្ឋមន្ត្រីស្ដីទីក្រសួងសុខាភិបាលចាប់ពីថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ១៩៩៤ រហូតដល់ ឯកឧត្តម ឈា ថាំង ត្រឡប់មកពីបំពេញភារកិច្ច នៅបរទេសវិញ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងរដ្ឋលេខាធិការអនុរដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តម ស៊ុយ សែម ត្រូវទទួលអនុវត្តសេចក្ដីសំរេចនេះចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

* * *

*រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ ១៩៩៤*

សេចក្ដីសំរេច លេខ ៦៩ ស ស រ

ស្ដីពី

ការបង្កើតគណៈកម្មការអន្តរក្រសួងសំរាប់អង្គារទប់ស្កាត់ និង បន្ថយ ជម្ងឺអេដស៍ និង ជម្ងឺកាមរោគ

*** ***

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ - ១១ - ៩៣

-បានឃើញព្រះរាជក្រឹត្យ ស្ដីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ ចុះថ្ងៃទី ២៤ - ០៩ - ៩៣ ។

- ផ្អែកតាមតម្រូវការចាំបាច់

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការអន្តរក្រសួងសំរាប់បង្ការ ទប់ស្កាត់ និង បន្ថយជម្ងឺអេដស៍ និង ជម្ងឺកាមរោគ ដែលមានសមាសភាពដូចខាងក្រោម :

១ - ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសុខាភិបាល ប្រធាន

២ - ឯកឧត្តមរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ អនុប្រធាន

៣ - ឯកឧត្តមរដ្ឋលេខាធិការ ក្រសួងពត៌មាន សមាជិក

៤ - ឯកឧត្តមរដ្ឋលេខាធិការ ក្រសួង អប់រំ សមាជិក

៥ - ឯកឧត្តមរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានកិច្ចការនារី សមាជិក

៦ - ឯកឧត្តមអនុរដ្ឋលេខាធិការ ក្រសួងទេសចរណ៍ សមាជិក

៧ - អភិបាលរងខេត្ត - ក្រុង និងរាជធានីភ្នំពេញ សមាជិក

ប្រការ ២ : គណៈកម្មការអន្តរក្រសួងសំរាប់បង្ការ ទប់ស្កាត់ និង បន្ថយជម្ងឺអេដស៍និងជម្ងឺកាមរោគមានលេខាធិការដ្ឋានជាជំនួយការ ដែលមានសមាសភាព ដូចខាងក្រោមនេះ :

១ - លោក វេជ្ជបណ្ឌិត ហ៊ុន ឈុនលី ប្រធានលេខាធិការដ្ឋាន

២ - លោក តំណាងក្រសួងមហាផ្ទៃ អនុប្រធាន

៣ - លោក តំណាង ក្រសួងអប់រំ សមាជិក

៤ - លោក តំណាង ក្រសួងពត៌មាន សមាជិក

៥ - លោក តំណាង ក្រសួងទេសចរណ៍ សមាជិក

៦- លោកស្រី តំណាងរដ្ឋលេខាធិការដ្ឋានកិច្ចការនារី សមាជិក

៧ - លោក វេជ្ជបណ្ឌិត ហោ ម៉ុនឡេង មន្ត្រីក្រសួងសុខាភិបាល សមាជិក

ប្រការ៣: គណៈកម្មការអន្តរៈក្រសួងសំរាប់ទប់ស្កាត់ និង បន្ថយជម្ងឺអេដស៍និងជម្ងឺ កាម រោគ មានភារកិច្ច:

-ទទួលខុសត្រូវរួមលើវិធានការការពារ និងព្យាបាល ទប់ស្កាត់ការរីករាល ដាល នៃជម្ងឺអេដស៍ និង ជម្ងឺកាមរោគ។

-ទទួលខុសត្រូវរួមលើវិធានការការពារ និងព្យាបាល ទប់ស្កាត់ការរីករាលដាល នៃជម្ងឺអេដស៍ និង ជម្ងឺកាមរោគ។

-ទទួលខុសត្រូវត្រួតពិនិត្យស្រាវជ្រាវ ជម្ងឺអេដស៍ជម្ងឺកាមរោគនិងធ្វើស្ថិតិ មេបនពេស្យានិងស្ត្រី ពេស្យា ក្នុងព្រះរាជាណាចក្រកម្ពុជា។

-លើកយោបល់ជូនរាជរដ្ឋាភិបាលកម្ពុជាអំពីបញ្ហាទាំងឡាយដែលទាក់ទង និងសភាពការណ៍ជម្ងឺអេដស៍ជម្ងឺកាមរោគ ពេស្យាចារនិងមេបនពេស្យា។

-ផ្តល់យោបល់ណែនាំដល់មន្ទីរពិសោធន៍ និង មន្ទីរពេទ្យដែលទទួលព្យាបាលថែទាំអ្នកផ្ទុក រោគអេច-អៃ-វ៊ី ឬ អ្នកកើតជម្ងឺអេដស៍ និង អ្នកកើតជម្ងឺកាម រោគ។

-ទទួលខុសត្រូវរៀបចំច្បាប់ និងលិខិតបទដ្ឋានស្តីពីការបង្កា ទប់ស្កាត់និងបន្ថយ ជម្ងឺអេដស៍ និងសកម្មភាពពេស្យាចារ ។

-ពិនិត្យអនុម័តលើគំរោងកម្មវិធីអប់រំ ដែលត្រូវធ្វើការ ផ្សព្វផ្សាយនៅតាមសាលារៀន តាមក្រសួងស្ថាប័ននានា តាមវិទ្យុ និងទូរទស្សន៍និងលើក កម្មវិធីអប់រំស្ត្រីពេស្យាដោយផ្ទាល់ ។

-ជំរុញការអនុវត្តនៅបណ្តាវិធានការ និង គោលការណ៍ទាំងឡាយដែលរាជ រដ្ឋាភិបាល បានដាក់ចុះ ។

<u>លេខាធិការដ្ឋាន មានភារកិច្ច</u> :

-ផ្តល់ពត៌មានអំពីសកម្មភាពនៃការអនុវត្តន៍ការងារបង្កា ទប់ស្កាត់និងបន្ថយជម្ងឺអេដស៍និងជម្ងឺកាមរោគ តាមកាលកំណត់ ជូនគណៈ កម្មការអន្តរក្រសួងនេះ ។

-រៀបចំខ្លឹមសារនិងរូបភាពសំរាប់ផ្សព្វផ្សាយតាមវិទ្យុ-ទូរទស្សន៍អោយបានទៀងទាត់និង សមស្របតាមប្រពៃណីជាតិចៀសវាងរូបអាស អាភាស

-រៀបចំខ្លឹមសារនិងរូបភាពសំរាប់បញ្ចូល ក្នុងកម្មវិធីសិក្សានៃ ភូមិសិក្សានានា និង សំរាប់ផ្សព្វផ្សាយតាម ក្រសួងស្ថាប័នអោយ ស្របតាមប្រពៃណីជាតិ។ ចំពោះ បនពេស្យា ត្រូវអនុវត្តន៍ដោយឡែក ។

-ទទួលខុសត្រូវក្នុងការតាមដាន និងអនុវត្តនូវសកម្មភាព ទាំងឡាយក្នុងកម្មវិធីបង្ការទប់ស្កាត់និងបន្ថយជំងឺអេដស៍ និងជម្ងឺកាមរោគតាមដំណាក់កាលនិមួយៗ ។

-សហការជាមួយក្រសួង មានសមត្ថកិច្ចក្នុង ការបង្ក្រាបមេបន និងអប់រំពេស្យាចារ ។

-លើកកម្មវិធីរយៈពេលខ្លី មធ្យម វែង ដើម្បីទប់ស្កាត់ការរីករាលដាលនៃជម្ងឺអេដស៍និងជម្ងឺកាមរោគ និងលើកគំរោងថវិកា សំរាប់ចំណាយក្នុងការងារនេះ ។

-សហការយ៉ាងជិតស្និទ្ធជាមួយ អង្គការសុខភាពពិភពលោកនិងអង្គការអន្តរជាតិនានាដើម្បីទាក់ទងសុំជំនួយឧបត្ថម្ភថវិកា ឧបករណ៍សំភារៈ សំរាប់បំរើកា រងារនេះ អោយដំណើរការ បាន ជាប់ជាប្រចាំ ។

-ធ្វើរបាយការណ៍អោយបានទៀងទាត់ រៀងរាល់ដំណាច់ខែជូនរាជរដ្ឋាភិបាលស្តីពីសភាពការណ៍វិវឌ្ឍន៍ និងរីកចំរើននៃសកម្មភាព របស់គណៈកម្មការអន្តរ ក្រសួងនេះ ។

ប្រការ ៤ : គណៈកម្មការអន្តរ ក្រសួងសំរាប់បង្ការទប់ស្កាត់ និងបន្ថយជម្ងឺអេដស៍ និងជម្ងឺកាមរោគ មានទីស្នាក់ការអចិន្ត្រៃយ៍ នៅក្រសួងសុខាភិបាល និងមានសិទ្ធប្រើប្រាស់ត្រារបស់ក្រសួងសុខាភិបាល ។

ប្រការ ៥ : សេចក្តីសំរេចលេខ ៣៦ សសរ ចុះថ្ងៃទី ១១-១២-៩៣ និង បទបញ្ញតិទាំងឡាយដែលផ្ទុយពីខ្លឹមសារនៃសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃក្រសួងអប់រំបណ្តា ក្រសួង-ស្ថាប័ននិងអភិបាល គ្រប់ខេត្ត ខេត្តក្រុង ដែលមានការពាក់ព័ន្ធព្រមទាំង ឯកឧត្តម អស់លោក លោកស្រី

ដែលមានរាយនាមក្នុង ប្រការ១ និង ប្រការ២ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃឡាយព្រះហស្តលេខានិងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * *

*រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩៤*

**សេចក្តីសំរេច លេខ ៧០ សសរ .ឧស**

**ស្តីពីការផ្ទេរសិទ្ធិ**

****

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច ព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា

-យោងតាមការងារចាំបាច់

**សំរេច**

ប្រការ ១ : ក្នុងឱកាសដែល ឯកឧត្តម ពូ សុធីរៈ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អញ្ជើញទៅបំពេញបេសកកម្មនៅឯបរទេស ចាប់ពីថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៩៤ ការងារប្រចាំថ្ងៃរបស់ក្រសួង ឧស្សាហកម្មរ៉ែ និង ថាមពលត្រូវបានផ្ទេរសិទ្ធិជូន ឯកឧត្តម នូន គានុន រដ្ឋលេខាធិការនៃទីស្តីការ គណៈរដ្ឋមន្ត្រី ជារដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល ស្តីទី រហូតដល់ពេលឯកឧត្តម ពូ សុធីរៈ អញ្ជើញត្រលប់មក មាតុភូមិវិញ ។